នាយកដ្ឋានសុខាភិបាលរដ្ឋ
Hawaiʻi

# វ៉ាក់សាំងដូសជំរុញឌីវ៉ាឡង់ បង្ការជំងឺ COVID-19



វ៉ាក់សាំងដូសជំរុញឌីវ៉ាឡង់ បង្ការជំងឺ COVID-19 ដែលត្រូវបានផលិតឡើងជាពិសេសដើម្បីបង្ការការពារជំងឺ COVID-19 ដើមនិងប្រភេទទូទៅបំផុតនៃមេរោគបំប្លែង ខ្លួន Omicron ត្រូវបានណែនាំឲ្យចាក់សម្រាប់មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ។

វ៉ាក់សាំងដូសជំរុញឌីវ៉ាឡង់ បង្ការជំងឺ COVID-19 ដែលបានធ្វើបច្ចុប្បន្នភាពអាចជួយស្តារសមត្ថភាពប្រព័ន្ធការពារដែលបានថយចុះចាប់តាំងពីការចាក់វ៉ាក់សាំងពីមុន និងផ្តល់សមត្ថភាពការពារកាន់តែខ្លាំងក្នុងការប្រឆាំងនឹងមេរោគបំប្លែង ខ្លួនថ្មី ជាពិសេសមេរោគបំប្លែង ខ្លួនថ្មី BA.4 និង BA.5 បន្តពីមេរោគបម្លែងខ្លួន Omicron។

វ៉ាក់សាំង និងវ៉ាក់សាំងដូសជំរុញ COVID-19 ដែលមានការអនុញ្ញាតទាំងអស់មានប្រសិទ្ធភាពក្នុងការកាត់បន្ថយហានិភ័យនៃជំងឺធ្ងន់ធ្ងរ ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់។

វ៉ាក់សាំង និងវ៉ាក់សាំងដូសជំរុញ COVID-19 គឺមិនគិតថ្លៃ និងអាចរកបាននៅបណ្តាឱសថស្ថាន មណ្ឌលសុខភាពសហគមន៍ គ្លីនិក និងអ្នកផ្តល់ សេវាថែទាំសុខភាពផ្សេងទៀតទូទាំងរដ្ឋនេះ។ អាចរកឃើញអ្នកផ្តល់សេវាចាក់វ៉ាក់សាំងនៅគេហទំព័រ vaccines.gov ។

## វ៉ាក់សាំងដូសជំរុញឌីវ៉ាឡង់ ត្រូវបានណែនាំឲ្យចាក់ក្នុងករណី...

- អាយុ 5 ឆ្នាំឡើងទៅ
- បានចាក់វ៉ាក់សាំងដូសមូលដ្ឋានរួចហើយ
- វាមានរយៈពេលយ៉ាងហោចណាស់ 2 ខែហើយចាប់តាំងពីអ្នកបានចាក់វ៉ាក់សាំងថ្មីៗបំផុត

## វ៉ាក់សាំង Pfizer ឬ Moderna?

អ្នកអាចជ្រើសរើសណាមួយក៏បាន! បុគ្គលម្នាក់ៗអាចទទួលបានទាំងវ៉ាក់សាំង Pfizer ឬ Moderna ដោយមិនគិតពីប្រភេទវ៉ាក់សាំងដែលពួកគេបានចាក់ពីមុន។

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន**
**HawaiiCOVID19.com/Vaccine**